អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០១៦

# សេចក្តីប្រកាសព័ត៌មាន
# ជប៉ុនផ្តល់ជំនួយថវិកាថ្មីចំនួន ១ ១២០ ០០០ ដុល្លារអាមេរិកដល់ អ.វ.ត.ក

រដ្ឋាភិបាលជប៉ុនបានប្រកាសផ្តល់វិភាគទានថ្មីចំនួន ១ ១២០ ០០០ ដុល្លារអាមេរិក ដល់ភាគីអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)។ វិភាគទានថ្មីនេះ បានធ្វើឱ្យជំនួយហិរញ្ញវត្ថុដែលផ្តល់ដោយរដ្ឋាភិបាលជប៉ុនមកកាន់ អ.វ.ត.ក (ទាំងភាគីជាតិ និងអន្តរជាតិ) កើនចំនួនដល់ប្រមាណ ៨៥ លានដុល្លារអាមេរិកហើយរហូតមកទល់ពេលនេះ ឬស្មើនឹង ៣២% នៃការផ្តល់វិភាគទានសរុបរបស់ក្រុមប្រទេសម្ចាស់ជំនួយ និងធ្វើឱ្យជប៉ុនក្លាយជាប្រទេសផ្តល់ជំនួយធំជាងគេបំផុតរបស់ អ.វ.ត.ក។

ឯកឧត្តម ក្រាញ់ តូនី ប្រធានការិយាល័យរដ្ឋបាលស្តីទី និងលោក ឃ្នុត រ៉ូហ្សិនហាក អនុប្រធានការិយាល័យរដ្ឋបាល មានប្រសាសន៍ថា៖ «ក្នុងនាម អ.វ.ត.ក យើងខ្ញុំសូមសម្តែងនូវការកោតសរសើរ និងអរគុណយ៉ាងស្មោះស្ម័គ្រចំពោះរដ្ឋាភិបាលជប៉ុន ដែលបានគាំទ្រនិងបន្តផ្តល់វិភាគទានហិរញ្ញវត្ថុដ៏មានសារៈសំខាន់នេះ។ ជំនួយហិរញ្ញវត្ថុថ្មីនេះ ពិតជាមានភាពចាំបាច់សម្រាប់ អ.វ.ត.ក ដើម្បីបញ្ចប់អាណត្តិការងាររបស់ខ្លួន ដោយមិនមានការរអាក់រអួលក្នុងកិច្ចដំណើរការនីតិវិធីឡើយ»។

*សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖*

លោកស្រី **ហាយ៉ាត់ អ្ហ៊ូប៊ូសាឡេស**
មន្ត្រីព័ត៌មាន
ទូរសព្ទចល័ត: +855 (0)12 488 936
សារអេឡិចត្រូនិក: abusaleh@un.org

លោក **នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរសព្ទចល័ត: +855 (0)12 488 156
សារអេឡិចត្រូនិក: neth.phektra@eccc.gov.kh